ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

លេខ ២១៣៨០ អពដ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សារលិខិតចូលរួមមរណទុក្ខ

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលោកជំទាវ អ៊ឹម ប៉ូលីកា**

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមខ្ញុំផ្ទាល់ យើងខ្ញុំទាំងអស់គ្នាមានសេចក្តីក្តុកក្តួល រន្ធត់ឥតឧបមា ដោយបានទទួលដំណឹងថា **ឯកឧត្តម អ៊ឹម សិទ្ធី** សមាជិកគណៈកម្មាធិការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ត្រូវជាឪពុក និងឪពុកក្មេក បានទទួលមរណភាពកាលពីវេលាម៉ោង ០៤:៤៥ នាទីព្រឹក ថ្ងៃសុក្រ ០៥ រោច ខែមិគសិរ ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ក្នុងជន្មាយុ ៧០ ឆ្នាំ ដោយរោគាពាធ។

ការបាត់បង់**ឯកឧត្តម អ៊ឹម សិទ្ធី** គឺជាការបាត់បង់ស្វាមី បិតា បិតាក្មេក ជីតា ជាទីគោរពស្រឡាញ់ និងប្រកបដោយព្រហ្មវិហារធម៌ និងទឹកចិត្តសណ្តោសប្រណីដ៏ថ្លៃថ្លា។

ស្ថិតក្នុងសមានទុក្ខ វិយោគសោកស្តាយរកទីបំផុតគ្មាននាឱកាសនេះ យើងខ្ញុំសូមចូលរួមសម្តែងមរណទុក្ខ និងក្តីអាឡោះអាល័យ ជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ និងសូមបួងសួងសូមវិញ្ញាណក្ខន្ធ**ឯកឧត្តម អ៊ឹម សិទ្ធី** ឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូមឯកឧត្តមបណ្ឌិតសភាចារ្យ ទេសរដ្ឋមន្ត្រី និងលោកជំទាវ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃសុក្រ ០៥ រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១

ត្រូវនឹងថ្ងៃទី០៨ ខែធ្នូ គ.ស. ២០១៧

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្សី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh